# អារម្ភកថា

សូមគោរព រាប់អាន លោកអ្នក យុវតីយុវជន និង បងប្អូន ទាំងអស់ ជាទីមេត្រី អត្ថបទ ទាំងឡាយដូចមានខាងក្រោមនេះ ខ្ញុំបានខំប្រឹងប្រែង ស្រាវជ្រាវ គិតគូរផ្សែផ្សំ សរសេរឡើង តាមដែលខ្ញុំបានរៀន បានយល់ កាលពីខ្ញុំនៅវ័យជានិស្សិត ផ្នែកគណិតសាស្រ្ត ដូចបងប្អូនកូនក្មួយខ្លះ ដែលកំពុងតែអានអារម្ភកថានេះដែរ។ ហេតុអ្វី បានជាខ្ញុំ សរសេរជាអត្ថបទ មិនសរសេរជាសៀវភៅ ពីព្រោះសៀវភៅត្រូវការពេលច្រើន ហើយដោយខ្ញុំមានអាយុកាន់តែច្រើនទៅហើយ ខ្ញុំខ្លាចស្លាប់មុនបានបោះពុម្ពសៀវភៅនោះ ចំណែកឯអត្ថបទ ត្រូវការពេលខ្លីជាង ហើយដោយសម័យនេះ មានអាំងតែណែត (internet) ផង នោះខ្ញុំអាចដាក់ផ្សាយបណ្ដើរៗ អត្ថបទដែលខ្ញុំបានសរសេររួចហើយ ។ តែអត្ថបទដែលនឹងចុះផ្សាយជាបន្តៗនោះ ក៏ជាប់ទាក់ទងនឹងអត្ថបទដើមៗដែរ ដូច្នេះថ្ងៃក្រោយយើងអាចប្រមូលផ្ដុំចងក្រងជាសៀវភៅក៏បានដែរ។

ម្យ៉ាងទៀត ហេតុដែលនាំឲ្យខ្ញុំសរសេរជាភាសាខ្មែរនោះ មកពីខ្ញុំចង់ជួយដល់លោកអ្នកអានដែលមានបញ្ហាក្នុងការយល់នូវភាសាបរទេស ហើយមួយទៀត ដោយខ្ញុំមានបំណងចង់ឲ្យខ្មែរយើងមានឯកសារជាភាសាខ្មែរ **ឲ្យកាន់តែច្រើន** គ្រប់មុខវិជ្ជា មិនត្រឹមតែមុខវិជ្ជាផ្នែកអក្សរសាស្រ្តខ្មែរតែប៉ុណ្ណឹងទេ ។

ដោយហេតុពាក្យខ្លះ ពុំទាន់មាននៅឡើយជាភាសាខ្មែរ នៅពេលដែលខ្ញុំសរសេរនោះ ឬមួយខ្ញុំពុំបានរកឲ្យបានគ្រប់កន្លែង នោះខ្ញុំសូមលោកអ្នកខាងអក្សរសាស្រ្តមេត្តាអភ័យទោសដល់ខ្ញុំផង ក្នុងការបកជាភាសាខ្មែរនូវពាក្យទាំងនោះ ។ តែចំពោះពាក្យខ្លះ ខ្ញុំក៏ពុំហ៊ានបកដែរ ខ្ញុំទុកនៅជាភាសាដើម គឺជាភាសាបារាំងដដែល។

អត្ថបទពីរខាងចុងនៃអត្ថបទទាំងឡាយ នឹងស្ដីពី សទ្ទានុក្រមមួយតូច ដែលនៅក្នុងនោះ មានពាក្យបច្ចេកទេសដែលខ្ញុំទុកជាភាសាបារាំង តែសរសេរជា **អក្សរខ្មែរ** ដូចជាពាក្យ ដេរីវេ (dérivée) ជាដើម ។ ហើយអត្ថបទចុងគេបង្អស់ គឺ រាយឈ្មោះសៀវភៅយោង

ដែលខ្ញុំបានអាន នូវទ្រឹស្តីនានា និងដកស្រង់នូវលំហាត់ខ្លះ មករកចម្លើយ សម្រាប់ជាឧទាហរណ៍ ជាជំនួយដល់ការយល់នូវទ្រឹស្តីទាំងនោះ ។ តែគប្បីរកលំហាត់ នៅសៀវភៅផ្សេងៗឯទៀតដោយខ្លួនឯង ហើយយកមកធ្វើ ដើម្បីនឹងទាញយកផលប្រយោជន៍ឲ្យបានជាអតិបរមា អំពីទ្រឹស្តីទាំងនោះ ។

ថ្ងៃ អាទិត្យ ទី ២៧ ខែ កញ្ញា ២០១៥

អាន តាំងគីម ។